ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

**លេខាធិការដ្ឋាន**

លេខ៖ ០០៤៧៨៩ /គ.ជ.អ.ប

*ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០២០*

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារដឹកនាំ និងសម្របសម្រួលបច្ចេកទេសអនុវត្តគម្រោងសមាហរណកម្មគណនេយ្យភាពសង្គមនៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

### ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែ កញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០១៥ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យ លេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យ លេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យ លេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់មុខងារគ្រប់គ្រង និងការផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

លេខាធិការដ្ឋាន

- យោងលិខិតលេខ៥២៩ ល.ស/គ.ជ.អ.ប ចុះថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- យោងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងផែនការអនុវត្តបីឆ្នាំដំណាក់កាលទី៣ (២០១៨-២០២០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៧
- យោងផែនការយុទ្ធសាស្ត្រស្ដីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០១៣
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៦-២០១៨ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៦
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣) ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៩។
- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង Grant Number-TFOB 2195-KH ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០២០ រវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារពិភពលោក ស្ដីពីការអនុវត្តគម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់របស់លេខាធិការដ្ឋាន គ.ជ.អ.ប

## សម្រេច

**ប្រការ ១._**

ត្រូវបង្កើតក្រុមការងារអនុវត្តគម្រោងសមាហរណកម្មគណនេយ្យភាពសង្គម ទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដើម្បីសម្របសម្រួល និងគាំទ្របច្ចេកទេស នៃការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផ.អ.គ.ស) ដំណាក់កាលទី២ (២០១៩-២០២៣)។

**ប្រការ ២._**

ក្រុមការងារអនុវត្តគម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាលេខាធិការ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងជាលេខាធិការគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ង៉ាន់ ចំរើន** | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | នាយកគម្រោង |
| ២-លោក **ម៉ាអុន ម៉ាអូណាត** | ប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន | ប្រធានគ្រប់គ្រងគម្រោង |
| ៣-លោក **ជេដ្ឋ គីមជុង** | អនុប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន | ប្រធានសម្របសម្រួលគម្រោង |

៤-លោកស្រី **ហេង សិទ្ធា** អនុប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃនិងព័ត៌មានទទួលបន្ទុកការងារលទ្ធកម្ម

៥-លោក **ទត វណ្ណៈ** អនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុង ទទួលបន្ទុកសវនកម្មផ្ទៃក្នុង

៦-លោក **ម៉ន ប៊ុនថារិទ្ធ** ប្រធានការិយាល័យទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មាន ទទួលបន្ទុកហិរញ្ញវត្ថុ

៧-លោក **សួង ថុន** ប្រធានការិយាល័យត្រួតពិនិត្យ និងវាយតម្លៃ ទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃ និងការងារសុវត្ថិភាពបរិស្ថាន សង្គម

៨-កញ្ញា **ផាន ស្រីរ័ត្ន** ប្រធានការិយាល័យព័ត៌មានវិទ្យា ទទួលបន្ទុកប្រព័ន្ធទិន្នន័យគណនេយ្យភាពសង្គម

៩-លោក **យាន យក់ធិន** ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបន្ទុកផែនការ ថវិកា និងសូចនាករថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

១០-លោក **ឆឹម សំអ៊ែល** អនុប្រធានការិយាល័យគ្រប់គ្រងគម្រោង ទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា

១១-លោក **ស៊ុយ ប៉ូលីន** អនុប្រធានការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ទទួលបន្ទុកទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

១២-លោក **ហេង ប៊ុនលី** អនុប្រធានការិយាល័យព័ត៌មានវិទ្យា ទទួលបន្ទុកជំនួយការហិរញ្ញវត្ថុ

១៣-លោក **អ៊ុក សុត្ថា** អនុប្រធានការិយាល័យត្រួតពិនិត្យ និងវាយតម្លៃ ទទួលបន្ទុកបេឡាករ

១៤-លោក **ចាន់ ប៉ូលីន** មន្ត្រីការិយាល័យរដ្ឋបាល និងសារពើភ័ណ្ឌ ទទួលបន្ទុកការងាររដ្ឋបាល

**ប្រការ ៣._ តួនាទី ភារកិច្ចរបស់ ក្រុមការងារដឹកនាំ និងសម្របសម្រួលបច្ចេកទេសអនុវត្តគម្រោងសមាហរណកម្មគណនេយ្យភាពសង្គមនៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានតួនាទី ភារកិច្ចដូចខាងក្រោម:**

- គាំទ្របច្ចេកទេស នៃការអនុវត្តសកម្មភាពផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការតាមគោលការណ៍នានា ព្រមទាំងផែនការសកម្មភាព និងថវិកា នៃផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- រៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពឧបករណ៍នានាពាក់ព័ន្ធទៅនឹងការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីដាក់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធអនុវត្ត និងប្រើប្រាស់។
- សម្របសម្រួលការងារទូទៅជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាដែលពាក់ព័ន្ធ។
- គាំទ្រការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការងារគណនេយ្យភាពសង្គម របស់លេខាធិការដ្ឋាន គ.ជ.អ.ប និងមូលនិធិបរធនបាលកិច្ច (Trust Fund)។
- ផ្តល់ការគាំទ្រ និងសម្របសម្រួលបច្ចេកទេសក្នុងការអភិវឌ្ឍសមត្ថភាព ពាក់ព័ន្ធទៅនឹងការអនុវត្តការងារគណនេយ្យភាពសង្គមដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- ជួបប្រជុំជាទៀងទាត់ និងរៀបចំរបាយការណ៍ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីវឌ្ឍភាព និងបញ្ហាប្រឈមនានា នៃដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម របស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលដៃគូអនុវត្តនានា។
- រៀបចំលិខិតបទដ្ឋាន គោលការណ៍ណែនាំនានា ស្តីពីការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។
- អនុវត្តតួនាទីភារកិច្ចផ្សេងៗទៀត ពាក់ព័ន្ធនឹងការអនុវត្តការងារគណនេយ្យភាពសង្គម ដែលថ្នាក់ដឹកនាំគម្រោងបានប្រគល់ជូន។
- កែសម្រួលឧបករណ៍សម្រាប់ចុះអភិបាលតាមបែបគាំទ្រការងារគណនេយ្យភាពសង្គម អោយសមស្របទៅតាមការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២។
- សហការជាមួយ អង្គការសង្គមស៊ីវិល រៀបចំសេចក្តីណែនាំ ស្តីពីការអនុវត្តលើសេវារដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងសេវាផ្សេងៗទៀតស្របតាមការផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការជាមួយអង្គការសង្គមស៊ីវិលដើម្បីរៀបចំដំណើរទស្សនកិច្ចសិក្សា ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (គ.គ.អ.ស) និងរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ គ.គ.អ.ស។

**ប្រការ ៤._**

អង្គភាពចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ២ មានភារកិច្ចត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យទទួលបានលទ្ធផលល្អប្រសើរ មានប្រសិទ្ធភាពខ្ពស់ ស្របទៅតាមតួនាទីភារកិច្ច លក្ខខណ្ឌបំពេញការងាររៀងៗខ្លួន និងផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានជាធរមាន។

**ប្រការ ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦._**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ង៉ាន់ ចំរើន**

**ចម្លងជូន៖**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងអប់រំ យុវជន និងកីឡា
-ក្រសួងសុខាភិបាល
-គណៈកម្មធិការ គ.គ.អ.ស
-អង្គភាពចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប
-ធនាគារពិភពលោក ប្រចាំកម្ពុជា
-អង្គការសង្គមស៊ីវិល ដៃគូអនុវត្ត I-SAF
-រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
"ដើម្បីជូនជ្រាប"
-ដូចប្រការ២ និងប្រការ៣ "ដើម្បីសហការអនុវត្ត"
-ឯកសារ កាលប្បវត្តិ